ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តសៀមរាប

សាលក្រមលេខៈ ៣២"ឃ"/២៩៦
ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២១
សំណុំរឿងរដ្ឋប្បវេណីលេខៈ ៩៣ ប.អ.ស
ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២១

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តសៀមរាប

កាលបរិច្ឆេទបញ្ចប់ទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២១
កាលបរិច្ឆេទប្រកាសសាលក្រមនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០២១ ។
**ចៅក្រមៈ** លោក [redacted]
**ក្រឡាបញ្ជីៈ** លោកស្រី [redacted]

**សហដើមចោទ ៖**

ឈ្មោះ [redacted] គីរី ភេទប្រុស កើតឆ្នាំ១៩៩០ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរលេខ ១៨០៥៣៨៩១៤ និងប្រពន្ធឈ្មោះ [redacted] ស្រីហ៊ាង ជនជាតិខ្មែរ មានអាសយដ្ឋាននៅ [redacted] ។

មេធាវីតំណាងដោយអាណត្តិលោក [redacted]

**សហចុងចម្លើយៈ**

ឈ្មោះ [redacted] ជានី ភេទស្រី កើតឆ្នាំ១៩៩៣ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរលេខ ១៨០៩៨២៧៩៨ និងប្តីឈ្មោះ [redacted] ធី ជនជាតិខ្មែរ មានអាសយដ្ឋាន [redacted] ។

មេធាវីតំណាងដោយអាណត្តិលោក [redacted] ។

## អង្គហេតុ និងចំណុចវិវាទ

១.ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ

-បង្គាប់ឲ្យសហចុងចម្លើយសងប្រាក់ដើមចំនួន ២៨,២៣៤$ (ពីរម៉ឺនប្រាំបីពាន់ពីររយសាមសិបបួនដុល្លាអាមេរិក) មកឲ្យសហដើមចោទ ។

-បង្គាប់ឲ្យសហចុងចម្លើយសងការប្រាក់ ១% ស្មើនឹងប្រាក់សរុបចំនួន ៥៦៤.៦៨$ (ប្រាំរយហុកសិបបួនក្បៀសហុកសិបប្រាំបីដុល្លាអាមេរិក) គិតចាប់ថ្ងៃទី០១ ខែមករា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១ ។

-បង្គាប់ឲ្យសហចុងចម្លើយសងជម្ងឺចិត្ត និងការខាតបង់ពេលវេលាចំនួន ៤០,០០០,០០០៛ (សែសិបលានរៀល) ។

-ស្នើសុំឲ្យតុលាការអនុវត្តបណ្ដោះអាសន្នត្រង់ចំណុចទី១ និងទី២ ។

-ឲ្យសហចុងចម្លើយទទួលបន្ទុកប្រាក់ប្រដាប់ក្ដី និងពន្ធ ។

២.ការពន្យល់ត្រួសៗអំពីរឿងក្ដី ៖

កាលពីអំឡុងឆ្នាំ២០២០ សហចុងចម្លើយឈ្មោះ [redacted] ជានី និងប្ដីឈ្មោះ [redacted] ជី តែងតែទិញផលិតផលអនឡាញ (គ្រឿងក្រអូប) ពីសហដើមចោទឈ្មោះ [redacted] គីរី និងប្រពន្ធឈ្មោះ [redacted] ស្រីហ៊ាង ជាបន្តបន្ទាប់រាល់ការទិញផលិតផលម្ដងៗ សហចុងចម្លើយមិនបានធ្វើការទូទាត់ប្រាក់នោះទេ ដោយចំនួនប្រាក់ជំពាក់មានចំនួនច្រើន សហចុងចម្លើយបានយល់ព្រមបង្កើតកិច្ចព្រមព្រៀង ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២០ ដោយសហចុងចម្លើយទទួលស្គាល់ប្រាក់ជំពាក់សហដើមចោទសរុបចំនួន ២៨,២៣៤$ (ពីរម៉ឺនប្រាំបីពាន់ពីររយសាមសិបបួនដុល្លារអាមេរិក) និងការប្រាក់១% ក្នុងមួយខែនៃប្រាក់ដើមសរុប ។ ក្នុងខ្លឹមសារនៃកិច្ចព្រមព្រៀង សហចុងចម្លើយយល់ព្រមសងប្រាក់មកឲ្យសហដើមចោទចំនួន ៥០០$ (ប្រាំរយដុល្លារអាមេរិក) ក្នុងមួយខែរហូតដល់សងគ្រប់ចំនួននៃប្រាក់ដើមដោយចាប់ផ្ដើមសងគិតពីថ្ងៃចុះកិច្ចព្រមព្រៀង ។

បន្ទាប់ពីបានចុះកិច្ចព្រមព្រៀងទទួលស្គាល់ប្រាក់ជំពាក់ខាងលើ សហចុងចម្លើយពុំបានអនុវត្តកាតព្វកិច្ចដូចដែលបានចែងក្នុងខ្លឹមសារនៃកិច្ចព្រមព្រៀងនោះទេ រហូតដល់ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២១ សហដើមចោទបានផ្ញើលិខិតជូនដំណឹងតាមរយៈលិខិតមេធាវីស្ដីពីការអនុវត្តកាតព្វកិច្ចសងប្រាក់ដើមចំនួន ២៨,២៣៤$ (ពីរម៉ឺនប្រាំបីពាន់ពីររយសាមសិបបួនដុល្លារអាមេរិក) ប៉ុន្តែរហូតមកដល់ពេលនេះ សហចុងចម្លើយតែងតែពន្យាពេលគេចវេស រកលេសដោះសារ និងគ្មានឆន្ទៈធ្វើការទូទាត់សងប្រាក់ដោយស្ម័គ្រចិត្តនោះទេ ។ បច្ចុប្បន្ននេះ ដោយសារតែការមិនអនុវត្តកាតព្វកិច្ចរបស់សហចុងចម្លើយហើយនឹងបញ្ហាជម្ងឺកូវីដ (COVID19) បានធ្វើឲ្យសហដើមចោទជួបការលំបាកក្នុងគ្រួសារយ៉ាងខ្លាំងដែលត្រូវខ្ចីប្រាក់ពីធនាគារ (ស្ថាបនា) និងបងប្អូនសាច់ញាតិយកទៅសងក្រុមហ៊ុន (គ្រឿងសំអាង) ជំនួសឲ្យសហចុងចម្លើយជារៀងរាល់ខែ ។

សហដើមចោទតែងតែព្យាយាមនិយាយលួងលោម សម្រុះសម្រួល ដើម្បីធ្វើការទូទាត់ប្រាក់ដោយសន្តិវិធីដើម្បីបញ្ចៀសការប្ដឹងទាមទារតាមផ្លូវតុលាការ ប៉ុន្តែសហចុងចម្លើយហាក់មិនខ្វាយខ្វល់ ព្រងើយកន្តើយ និងថែមទាំងជម្រុញសហដើមចោទធ្វើការដាក់ពាក្យប្ដឹងថែមទៀតផង ។ ទង្វើរបស់សហចុងចម្លើយបានធ្វើឲ្យសហដើមចោទបាត់បង់ជំនឿចិត្តក្នុងការទាមទារប្រាក់ពីសហចុងចម្លើយបានជំពាក់ ឬការអនុវត្តសិទ្ធិលើបំណុលក៏សម្រេចចិត្តដាក់ពាក្យបណ្ដឹងមកតុលាការដើម្បីជួយរកដំណោះស្រាយ និងស្វែងរកភាពយុត្តិធម៌ដល់សហដើមចោទដែលជាជនរងគ្រោះ ។

៣.ការអះអាងរបស់គូភាគី

ក.ការអះអាងរបស់ដើមចោទ

-ឈ្មោះ [redacted] គីរី និងឈ្មោះ [redacted] ស្រីហ៊ាង ជាដើមចោទថ្លែងការណ៍ថា ៖ សុំឲ្យតុលាការចេញសាលក្រមដូចខាងក្រោម៖

១-បង្គាប់ឲ្យសហចុងចម្លើយសងប្រាក់ដើមចំនួន ២៨,២៣៤$ (ពីរម៉ឺនប្រាំបីពាន់ពីររយសាមសិបបួនដុល្លាអាមេរិក) មកឲ្យសហដើមចោទ ។

២-បង្គាប់ឲ្យសហចុងចម្លើយសងការប្រាក់ ១% ស្មើនឹងប្រាក់សរុបចំនួន ៥៦៤.៦៨$ (ប្រាំរយហុកសិបបួនក្បៀសហុកសិបប្រាំបីដុល្លាអាមេរិក) គិតចាប់ថ្ងៃទី០១ ខែមករា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១ ។

៣-បង្គាប់ឲ្យសហចុងចម្លើយសងជម្ងឺចិត្ត និងការខាតបង់ពេលវេលាចំនួន ៤០,០០០,០០០៛ (សែសិបលានរៀល) ។

៤-ស្នើសុំឲ្យតុលាការអនុវត្តបណ្តោះអាសន្នត្រង់ចំណុចទី១ និងទី២ ។

៥-ឲ្យសហចុងចម្លើយទទួលបន្ទុកប្រាក់ប្រដាប់ក្តី និងពន្ធ ។

ខ.ការអះអាងរបស់មេធាវីតំណាងដោយអាណត្តិឲ្យដើមចោទ

-លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឲ្យដើមចោទថ្លែងការណ៍ថា ៖ភាគីចុងចម្លើយបានទទួលស្គាល់ប្រាក់ដើមចំនួន ២៨,២៣៤$ (ពីរម៉ឺនប្រាំបីពាន់ពីររយសាមសិបបួនដុល្លាអាមេរិក) និងយល់ព្រមសងមកឲ្យសហដើមចោទ ប៉ុន្តែនៅមានចំណុចវិវាទ២ គឺការទាមទារការប្រាក់ និងការទាមទារសំណងជម្ងឺចិត្ត ភាគីចុងចម្លើយបានស្នើសុំឲ្យដើមចោទលះបង់ តែភាគីដើមចោទនៅតែស្នើសុំរក្សានៅដដែលដោយសំអាងថា ការទាមទារការប្រាក់គឺ មាននៅក្នុងកិច្ចព្រមព្រៀង ហើយការទាមទារសំណងជម្ងឺចិត្តគឺដោយសារភាគីចុងចម្លើយធ្វើឲ្យសហដើមចោទខាតបង់ការប្រាក់ ពេលវេលា និងសោហ៊ុយសេវាផ្លូវច្បាប់ ហេតុនេះសហចុងចម្លើយគប្បីសងការខូចខាតជាសាច់ប្រាក់ជូនល្មមមកឲ្យសហដើមចោទ ។

គ.ការអះអាងរបស់មេធាវីតំណាងដោយអាណត្តិឲ្យចុងចម្លើយ

-លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឲ្យចុងចម្លើយថ្លែងការណ៍ថា ៖ ទទួលស្គាល់ប្រាក់ដើម ចំណែកឯការប្រាក់ និងសំណងជម្ងឺចិត្តសុំតុលាការច្រានចោល ដោយសារការយកទំនិញមកលក់នោះមានការខាតបង់ រកប្រាក់ចំណូលមិនបាន ដោយបញ្ហានេះហើយទំនិញត្រូវលក់ឡើងឡុងមិនបានដើមហើយទំនិញខ្លះហួសដីឡេ ។

ហេតុនេះខ្លួនសុំច្រានចោលការទាមទារការប្រាក់ និងសំណងជម្ងឺចិត្ត ។

៤.ចំណុចវិវាទ ៖ ការទាមទារការប្រាក់ និងការទាមទារសំណងជម្ងឺចិត្ត ។

៥.ការពិនិត្យកស្តុតាង

-សៀវភៅស្នាក់នៅលេខ ៩៩០៩/១៩ ន.បស.បា.គ ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ ។

-កិច្ចសន្យាសងប្រាក់ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២០ ។

-កិច្ចព្រមព្រៀង ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២០ ។

-លិខិតជូនដំណឹង ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០២១ ។

-តារាងបង់ប្រាក់ធនាគារស្ថាបនា ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២០ ។

## សំអាងហេតុ

តាមលទ្ធផលនៃការពិនិត្យកស្តុតាងក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ឃើញថា ៖

១-តាមកិច្ចសន្យាសងប្រាក់ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២០ និងកិច្ចព្រមព្រៀង ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២០ ព្រមទាំងការអះអាងរបស់លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឲ្យដើមចោទថា ៖ សហចុងចម្លើយ ពិតជាបានជំពាក់ប្រាក់ដើមដែលបានទិញផលិតផលអនឡាញពីសហដើមចោទដែលជាម្ចាស់ផលិតផលក្នុងទឹកប្រាក់ចំនួន ២៨,២៣៤$ (ពីរម៉ឺនប្រាំបីពាន់ពីររយសាមសិបបួនដុល្លាអាមេរិក) ហើយសហចុងចម្លើយមិនទាន់បានប្រគល់ប្រាក់ដើមនោះទៅឲ្យដើមចោទនៅឡើយទេ ហើយការទាមទារប្រាក់ដើមនេះ ក៏ត្រូវបានភាគីចុងចម្លើយឯកភាពទទួលស្គាល់ ។

ដូច្នេះតុលាការគប្បី សម្រេចតាមការទាមទាររបស់សហដើមចោទ ដោយបង្គាប់ឲ្យសហចុងចម្លើយសងប្រាក់ដើមចំនួន ២៨,២៣៤$ (ពីរម៉ឺនប្រាំបីពាន់ពីររយសាមសិបបួនដុល្លាអាមេរិក) មកឲ្យសហដើមចោទ ។

២-ចំពោះការទាមទារការប្រាក់ដែលជាចំណុចវិវាទឃើញថា ភាគីដើមចោទបានស្នើសុំអត្រាការប្រាក់ចំនួន ០១%(មួយភាគរយ) នៃប្រាក់ដើមក្នុង០១ខែ តាមកិច្ចព្រមព្រៀង ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២០ ដែលបានបង្កើតឡើងដោយឆន្ទៈរបស់គូភាគីនៃកិច្ចព្រមព្រៀងរវាងឈ្មោះ [redacted] ស្រីហ៊ាង និងឈ្មោះ [redacted] ជានី ដែលបានជំពាក់ប្រាក់ដើមចំនួន ២៨,២៣៤$ (ពីរម៉ឺនប្រាំបីពាន់ពីររយសាមសិបបួនដុល្លាអាមេរិក) ដោយគិតអត្រាការប្រាក់ ១% ក្នុងមួយខែនៃប្រាក់ដើម តែការទាមទារនេះត្រូវបានភាគីចុងចម្លើយបានស្នើសុំឲ្យដើមចោទលះបង់ដោយសំអាងថាខ្លួនបានរកស៊ីខាត តែភាគីដើមចោទមិនព្រមលះបង់ទេ នៅតែសុំទាមទារដដែល ។ ការទាមទារការប្រាក់នេះ តុលាការយល់ឃើញថា ភាគីដើមចោទបានទាមទារការប្រាក់ ១% ក្នុងមួយខែនៃប្រាក់ដើម គឺស្មើនឹង ១២% ក្នុងមួយឆ្នាំ ដែលការទាមទារនេះមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ស្របតាមប្រការ១ និង ប្រការ២ នៃប្រកាសស្តីពីអត្រាការប្រាក់ដែលត្រូវបានកម្រិត ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១។

ដូច្នេះតុលាការគប្បី សម្រេចតាមការទាមទាររបស់សហដើមចោទ ដោយបង្គាប់ឲ្យសហចុងចម្លើយសងការប្រាក់ ១%(មួយភាគរយ)នៃប្រាក់ដើមចំនួន ២៨,២៣៤$ (ពីរម៉ឺនប្រាំបីពាន់ពីររយសាមសិបបួនដុល្លាអាមេរិក) ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២១ រហូតដល់សងប្រាក់ដើមគ្រប់ចំនួន ។

៣-ចំពោះការទាមទារសំណងជម្ងឺចិត្ត និងការខាតបង់ពេលវេលាចំនួន ៤០,០០០,០០០៛ (សែសិបលានរៀល) របស់ភាគីដើមចោទ ឃើញថា ភាគីចុងចម្លើយស្នើសុំឲ្យលះបង់ តែភាគីដើមចោទស្នើរក្សាដដែល តុលាការយល់ឃើញថា សកម្មភាពរបស់ភាគីចុងចម្លើយបានធ្វើឲ្យដើមចោទខាតបង់ពេលវេលា និងសោហ៊ុយមេធាវី ដូច្នេះតុលាការគប្បីសម្រេចពីសំណងខូចខាត ទៅតាមទំហំ[illegible]របស់សហដើមចោទ

និងលទ្ធភាពរបស់សហចុងចម្លើយ ដោយបង្គាប់ឲ្យសហចុងចម្លើយសងជម្ងឺចិត្ត និងការខាតបង់ពេលវេលា ចំនួន ៤,០០០,០០០៛ (បួនលានរៀល) ការទាមទារលើសពីនេះសម្រេចច្រានចោល។

៤-ដើមចោទស្នើសុំអនុវត្តបណ្ដោះអាសន្នត្រង់ចំណុចទី១ និងទី២ តុលាការយល់ឃើញថា ការទាមទារចំណុចទី១ទៅលើប្រាក់ដើម គឺភាគីបានព្រមព្រៀងទទួលស្គាល់ការទាមទារនេះ ស្របតាមមាត្រា ១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ការទាមទារចំណុចទី១នេះមានលក្ខណៈចាំបាច់ ដូច្នេះតុលាការប្រកាសថា សាលក្រមនេះអាចអនុវត្តជាបណ្ដោះអាសន្នបានត្រង់ចំណុច១ ហើយចំណុច២ ការទាមទារការប្រាក់ តុលាការយល់ឃើញថាពុំចាំបាច់ប្រកាសអនុវត្តជាបណ្ដោះអាសន្នទេ ។

៥-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ភាគីសហចុងចម្លើយ តាមមាត្រា៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

## សេចក្ដីសម្រេចបញ្ចប់

១/.បង្គាប់ឲ្យសហចុងចម្លើយសងប្រាក់ដើមចំនួន ២៨,២៣៤$ (ពីរម៉ឺនប្រាំបីពាន់ពីររយសាមសិបបួនដុល្លាអាមេរិក) មកឲ្យសហដើមចោទ។

២/.បង្គាប់ឲ្យសហចុងចម្លើយសងការប្រាក់ ១%(មួយភាគរយ)នៃប្រាក់ដើមចំនួន ២៨,២៣៤$ (ពីរម៉ឺនប្រាំបីពាន់ពីររយសាមសិបបួនដុល្លាអាមេរិក) ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២១ រហូតដល់សងប្រាក់ដើមគ្រប់ចំនួន ។

៣/.បង្គាប់ឲ្យសហចុងចម្លើយសងជម្ងឺចិត្ត និងការខាតបង់ពេលវេលាចំនួន៤,០០០,០០០៛ (បួនលានរៀល) ឲ្យទៅសហដើមចោទនៅពេលសាលក្រមចូលជាស្ថាពរ ។ ការទាមទារលើសពីនេះច្រានចោល ។

៤/.សាលក្រមនេះអាចអនុវត្តបណ្ដោះអាសន្នបានត្រង់ចំណុច ១ ។

៥/.ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់សហចុងចម្លើយ ។

សាលក្រមនេះបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២១ និងប្រកាសជាសាធារណៈចំពោះមុខមេធាវីតំណាងដោយអាណត្តិឲ្យភាគីសហដើមចោទ និងមេធាវីតំណាងដោយអាណត្តិឲ្យសហចុងចម្លើយនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០២១ ។

ថ្ងៃអង្គារ ២កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥
សៀមរាប,ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២១

**ចៅក្រម**

ហត្ថលេខា និងត្រា: [redacted]

បានឃើញ
ចៅក្រម

[redacted]

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃអង្គារ ២កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥
សៀមរាប,ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២១
ក្រឡាបញ្ជី

[redacted]